## យុទ្ធសាស្ត្រ និងវិធីសាស្ត្ររបស់យើង



យោងតាមទ្រឹស្តីនៃការផ្លាស់ប្តូរខាងលើ យើងមានយុទ្ធសាស្ត្រចំនួន៦ ដើម្បីសម្រេចបានគោលដៅ កំណត់បានលទ្ធផលជាក់លាក់ និងសម្រេចបានផលជះយូរអង្វែង។ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រ ៥ឆ្នាំនេះ យើងនឹងរួមចំណែកបង្កើត បរិយាកាស នយោបាយល្អ បង្កើនការគាំទ្រផ្នែកគោលនយោបាយ ស្វែងរកប្រភពហិរញ្ញប្បទានថ្មីៗ និងបង្កើតផលិតផល និងសេវាកម្មបរិស្ថានដែលមាននិរន្តរភាព។ កិច្ចការនេះ នឹងបង្កើតជាវដ្ត និងការរីកចម្រើនដល់សហគ្រាសសហគមន៍ ។ ដូចគ្នាដែរ វានឹងជំរុញឱ្យមានការវិនិយោគបន្ថែមពីរដ្ឋនិងវិស័យឯកជន លើការគ្រប់គ្រងតំបន់ទេសភាពព្រៃឈើដោយមានការចូលរួមពីសហគមន៍ ដែលនឹងជំរុញការអនុវត្តសហគមន៍ព្រៃឈើ ឱ្យមាននិរន្តរភាព និងដោះស្រាយបញ្ហាយេនឌ័រ ក៏ដូចជាគាំទ្រដល់សមាជិកដែលងាយរងគ្រោះផងដែរ។

### ១. ធានាថាតំបន់ទេសភាពព្រៃឈើរួមចំណែកដំណោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

យើងនឹងបន្តលើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍ ជាដំណោះស្រាយសម្រាប់បញ្ហាប្រែប្រួលអាកាសធាតុ ក៏ដូចជាបង្កើនភាពធន់ និងសមត្ថភាពបន្សាំរបស់សហគមន៍មូលដ្ឋាន។

### ២. ការពារសិទ្ធិ និងអភិបាលកិច្ចប្រកបដោយបរិយាប័ន្ន

យើងនឹងធ្វើការកំណត់ និងដោះស្រាយចន្លោះប្រហោង និងចំណុចដែលត្រូវបំពេញបន្ថែមក្នុងក្របខ័ណ្ឌច្បាប់។ យើងនឹងកៀរគរឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងដំណើរការសម្រេចចិត្ត បង្កើនភាពអង់អាចដល់សហគមន៍ ជាពិសេសជួយដល់ ក្រុមងាយរងគ្រោះ លើកឡើងពីភាពកង្វល់ និងតម្រូវការរបស់ពួកគេ ។

### ៣. គាំទ្រការរីកចម្រើនអាជីវកម្មនៅតំបន់ទេសភាពព្រៃឈើ

យើងនៅតែបន្តគាំទ្រសហគមន៍បង្កើត និងគ្រប់គ្រងសហគ្រាស អនុផលនិងសេវាកម្មព្រៃឈើ។ យើងនឹងសម្របសម្រួលភាពជាដៃគូដោយសមធម៌ រវាងសហគមន៍ និងតួអង្គក្នុងខ្សែចង្វាក់ផលិតកម្ម ព្រមទាំងលើកកម្ពស់គណនេយ្យភាព និងការបែងចែកផលប្រយោជន៍ដោយស្មើភាព។

### ៤. ធានាហិរញ្ញវត្ថុសម្រាប់និរន្តរភាពតំបន់ទេសភាពព្រៃឈើ

យើងនឹងបង្ហាញអំពីផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ សង្គម និងបរិស្ថានដែលបានពីការវិនិយោគក្នុងការគ្រប់គ្រងតំបន់ទេសភាពព្រៃឈើប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព។ យើងនឹងគាំទ្រសហគមន៍ ក្នុងការអនុវត្តគំរូអាជីវកម្មផ្សេងៗ និងការគ្រប់គ្រងហិរញ្ញវត្ថុកម្រិតសហគមន៍។

### ៥. បង្កើតភស្តុតាងសម្រាប់បង្ហាញ

យើងនឹងបន្តបង្កើត និងផ្សព្វផ្សាយចែករំលែកភស្តុតាងពីផលប្រយោជន៍ និងការអនុវត្តប្រកបដោយបរិយាប័ន្ន និងនិរន្តរភាពនៅតំបន់ទេសភាពព្រៃឈើ ក៏ដូចជាការស្តារព្រៃឈើឡើងវិញ។

### ៦. កៀរគរសាធារណៈជនឲ្យយល់ពីបញ្ហាក្នុងតំបន់ទេសភាពព្រៃឈើ

យើងនឹងបង្កើនការទទួលស្គាល់ពីទំនួលខុសត្រូវរបស់សហគមន៍សម្រាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងតម្លៃនៃផលិតផល និងសេវាកម្មរបស់សហគមន៍។ យើងនឹងបង្កើនការយល់ដឹង ជាពិសេសក្នុងចំណោមស្ត្រី យុវជន និងក្រុមជនជាតិដើម និងសហគមន៍មូលដ្ឋានអំពីឱកាសផ្នែកសេដ្ឋកិច្ចក្នុងតំបន់ទេសភាពព្រៃឈើ និងលើកទឹកចិត្តពួកគេចូលរួមក្នុងតួនាទីជាអ្នកដឹកនាំក្នុងវិស័យកសិកម្ម ព្រៃឈើនិងសេវាកម្មបរិស្ថាន។

**ស្វែងយល់បន្ថែម**

អានឯកសារពេញរបស់
**ផែនការយុទ្ធសាស្ត្រ**
RECOFTC ២០២៣-២០២៨

recoftc.org


**ការិយាល័យថ្នាក់តំបន់**

ប្រអប់សំបុត្រលេខ ១១១១ ប៉ុស្តិ៍ប្រៃសណីយ៍កាសេតសាត
ទីក្រុងបាងកក ១០៩០៣ ប្រទេសថៃ
ទូរស័ព្ទ៖ +៦៦ (០)២ ៩៤០ ៥៧០០
ទូរសារ៖ +៦៦ (០)២ ៥៦១ ៤៨៨០
info@recoftc.org
@RECOFTC

**រីខូហ្វកម្ពុជា**

រដ្ឋបាលព្រៃឈើ
អាគារលេខ៤០ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារកណ្តាល២
ភ្នំពេញ, កម្ពុជា
លេខទូរស័ព្ទទំនាក់ទំនង +៨៥៥ (០)២៣ ៩៩៨ ៧៨៤



ម្ចាស់ជំនួយ

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

Sweden
Sverige

ការងាររបស់ RECOFTC អាចធ្វើទៅបានដោយមានការគាំទ្រពីទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការស្វីស (SDC) និងទីភ្នាក់ងារស៊ុយអែតសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ (Sida)


RECOFTC

# ផែនការយុទ្ធសាស្ត្រ
# ២០២៣-២០២៨





ចំណុចសំខាន់ៗ

RECOFTC បានធ្វើការងារសហគមន៍ព្រៃឈើ អស់រយៈពេល៣៦ឆ្នាំ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដោយមានការិយាល័យនៅ ប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ឡាវ មីយ៉ាន់ម៉ា ណេប៉ាល់ ថៃ និងវៀតណាម។ ចក្ខុវិស័យរបស់យើងគឺ សហគមន៍មូលដ្ឋានមានលទ្ធភាព និងសិទ្ធិក្នុងការគ្រប់គ្រងតំបន់ទេសភាពព្រៃឈើដោយនិរន្តរភាពនិងសមធម៌។ បេសកកម្មរបស់យើង គឺពង្រឹងសមត្ថភាព លើកកម្ពស់សិទ្ធិ និងអភិបាលកិច្ច ដើម្បីធានាថាប្រជាសហគមន៍ទទួលបានប្រយោជន៍ដោយសមធម៌ពីតំបន់ទេសភាពព្រៃឈើដែលពួកគេចូលរួមគ្រប់គ្រង។

យើងប្រើប្រាស់អភិក្រមការងាររយៈពេលវែង ប្រកបដោយបរិយាប័ន្ន និងមានភាពគ្រប់ជ្រុងជ្រោយក្នុងតំបន់ទេសភាពព្រៃឈើ ដើម្បីគាំទ្រសហគមន៍មូលដ្ឋានការពារសិទ្ធិលើដីធ្លី និងធនធានធម្មជាតិ កាត់បន្ថយការបាត់បង់ព្រៃឈើ បង្កើនជីវភាព និងជម្រុញអោយមានសមភាពយេនឌ័រ។ RECOFTC ត្រូវបានផ្តល់ទំនុកចិត្ត និងជឿជាក់ថា ជាអង្គការអន្តរជាតិដែលជួយគាំទ្រ ផ្តល់ព័ត៌មាន និងសម្របសម្រួលអោយមានកិច្ចសន្ទនាប្រកបដោយភាពស្ថាបនារវាង ភ្នាក់ងាររដ្ឋាភិបាល សហគមន៍មូលដ្ឋាន អ្នកធុរៈកិច្ច គ្រឹះស្ថានអប់រំ និងអង្គការសង្គមស៊ីវិល។

## បរិបទ-បញ្ហាប្រឈម និងឱកាស

តំបន់អាស៊ីប៉ាស៊ីហ្វិក កំពុងប្រឈមនឹងបញ្ហាបរិស្ថាន និងសេដ្ឋកិច្ចជាច្រើនដែលធ្វើឲ្យវិសមភាពសង្គមកាន់តែកើនឡើង។ វិបត្តិការប្រែប្រួលអាកាសធាតុដូចជាទឹកជំនន់ ភាពរាំងស្ងួត នាំមកនូវហានិភ័យយ៉ាងខ្លាំង ចំពោះសន្តិសុខស្បៀងអាហារ និងសុខភាពសាធារណៈ។បញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរដោយសារអស្ថេរភាពទីផ្សារ និងការកើនឡើងសម្ពាធសង្គមលើធនធានដែលបណ្តាលមកពីផលប៉ះពាល់លើសេដ្ឋកិច្ចពីជំងឺរាតត្បាត កូវីដ-១៩ និងជម្លោះភូមិសាស្ត្រនយោបាយ។ នៅក្នុងស្ថានភាពដ៏ស្មុគស្មាញនេះស្ត្រី ជនជាតិដើម និងយុវជន មានការពិបាកក្នុងការចូលរួម និងទទួលផលប្រយោជន៍ពីចង្វាក់ផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព។ ក្នុងន័យនេះ រីខូហ្វ(RECOFTC) មានសមត្ថភាពរួមចំណែកក្នុងការដោះស្រាយបញ្ហាទាំងនេះ ដោយសារយើង មានបទពិសោធន៍ជាច្រើន លើការងារអភិបាលកិច្ចធនធាន ការគាំទ្រការចូលរួមរបស់សហគមន៍ និងការគាំទ្រការលើកកម្ពស់សុវត្ថិភាពសង្គម។

បើទោះជាមានបញ្ហាប្រឈមទាំងនេះ ក៏យើងសង្កេតឃើញមានការកើនឡើងនូវការយកចិត្តទុកដាក់ ពីតួនាទីព្រៃឈើក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងការបាត់បង់ជីវៈចម្រុះ។ ការខិតខំប្រឹងប្រែងនេះគឺស្របទៅតាមការប្តេជ្ញាចិត្តអន្តរជាតិ ដូចជាកិច្ចព្រមព្រៀងទីក្រុងប៉ារីស ក្នុងការបង្កើនធនធានព្រៃឈើ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ គោលនយោបាយថ្មីៗ បានពង្រឹងអំណាចដល់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងព្រៃឈើ ស្របពេលដែលមានការកើនឡើងការប្រើប្រាស់ប្រព័ន្ធឌីជីថល និងជម្រុញឱ្យមានតម្លាភាពក្នុងការងារអភិបាលកិច្ច។ ប្រភពហិរញ្ញប្បទាន ដូចជាមូលនិធិបៃតង (Green Funds) និងឥណទានកាបូន (carbon credits)សុទ្ធសឹងជាសក្តានុពលដែលគាំទ្រដល់ការដោះស្រាយបញ្ហាដែលកំពុងកើតឡើងទាំងនេះ។ RECOFTC នឹងប្រើប្រាស់ឱកាសទាំងអស់នេះ ដើម្បីគាំទ្រការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពនិងលើកកម្ពស់ការចូលរួមពីប្រជាសហគមន៍។






## ឆ្ពោះទៅរកអនាគតល្អប្រសើរ៖ គោលដៅទាំងបួន

RECOFTC មានគោលដៅការងារចំនួន៤ ដើម្បីរួមចំណែកដល់ផលជះដែលយើងចង់សម្រេចបានគឺ សហគមន៍មូលដ្ឋាន គ្រប់គ្រងតំបន់ទេសភាពព្រៃឈើប្រកបដោយនិរន្តរភាព និងសមធម៌ ដោយសហការជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីធានាថាតំបន់ទេសភាពព្រៃឈើ ផ្តល់ប្រយោជន៍ជាផលិតផល និងសេវាកម្មដល់សមាជិកសហគមន៍ និងប្រជាជនទាំងអស់ព្រមទាំងរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការអភិរក្សជីវៈចម្រុះ។

### គោលដៅទី ១ - ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

សហគមន៍រួមចំណែក ដល់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ពង្រឹងសមត្ថភាពសម្របខ្លួននឹងការប្រែប្រួល ការអភិរក្សជីវៈចម្រុះ និងការរក្សាសេវាកម្មអេកូឡូស៊ីពីតំបន់ទេសភាព។

### គោលដៅទី ២ - លើកកម្ពស់សមភាពយេនឌ័រនិងបរិយាប័ន្នសង្គម

សហគមន៍មូលដ្ឋានជាពិសេស សមាជិកសហគមន៍ដែលជាក្រុមងាយរងគ្រោះ ទទួលបានសិទ្ធិរបស់គេ ដើម្បីរស់នៅក្នុង និងជុំវិញតំបន់ព្រៃឈើ មានតួនាទីជាអ្នកដឹកនាំក្នុងការគ្រប់គ្រងតំបន់ទេសភាពព្រៃឈើឱ្យមាននិរន្តរភាព និងទទួលបានផលប្រយោជន៍ប្រកបដោយសមធម៌ពីតំបន់ទេសភាពព្រៃឈើទាំងនេះ។

### គោលដៅទី ៣ - ពង្រឹងអភិបាលកិច្ច និងការគោរពសិទ្ធិ

សហគមន៍មូលដ្ឋាន រួមចំណែកដល់និងទទួលប្រយោជន៍ពីស្ថាប័ន គោលនយោបាយ និងច្បាប់ ដែលការពារនិងគោរពសិទ្ធិរបស់ពួកគេ។ រដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋានអនុវត្តតាមគោលការណ៍អភិបាលកិច្ចល្អសម្រាប់តំបន់ទេសភាពព្រៃឈើ។

### គោលដៅទី ៤ - បង្កើនផលប្រយោជន៍សេដ្ឋកិច្ចជូនដល់សហគមន៍

សហគមន៍ទទួលបានផលប្រយោជន៍ពីធនធានព្រៃឈើដូចជាមាន ការងារ ការអភិវឌ្ឍសហគ្រាស ការទទួលបានហិរញ្ញប្បទាននិងការសហការជាមួយវិស័យឯកជន ក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ចបៃតង។

## ទ្រឹស្តីនៃការផ្លាស់ប្តូរ

តាមរយៈទ្រឹស្តីការផ្លាស់ប្តូរ យើងពង្រីកជាអតិបរមាសម្រាប់ប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានក្នុងតំបន់ទេសភាពព្រៃឈើ ដោយពង្រឹងអំណាចសហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រង និងទទួលប្រយោជន៍ពីតំបន់ទេសភាពទាំងអស់នេះ។

